*(ការបកប្រែក្រៅផ្លូវការ ដោយ គណកម្មាធិការព្រំដែនកម្ពុជា ប្រទេសបារាំង)*

# B.M.D.

# នរោត្តម សីហនុ

ប៉េកាំង ទី១៦ ខែមិនា ២០០៥

ក្នុងពេលបច្ចុប្បន្ននេះ គ្មាននរណាម្នាក់ដែលអាចនឹងប្រកែកបានឡើយ ពីការបាត់បង់បូរណភាពទឹកដី មួយភាគធំ ដោយប្រទេសកម្ពុជា"រាជាណាចក្រ ទី២" ទាំងខាងដែនដីគោក ទាំងខាងផ្ទៃកដែនសមុទ្រ បូរណ-ភាពទឹកដី ដែលមានចាប់ពីឆ្នាំ១៩៦៣មក (ជាមួយនឹងការត្រឡប់មកវិញ នៃប្រាសាទព្រះវិហារ) ។

ក្នុងពេលបច្ចុប្បន្ននេះ គេបានដឹងយ៉ាងច្បាស់ថា មួយភាគធំនៃទឹកដីនិងសមុទ្ររបស់យើង ដែលយើងមាន ពីឆ្នាំ១៩៦៣-១៩៦៩ នោះ ត្រូវបានគេកាត់យក ទៅបញ្ចូលទាំងកំរោល ទៅក្នុងអ្វីដែលហៅថា "អធិប-តេយភាព" នៃប្រទេសជិតខាងយើងទាំង៣ (ប្រទេសថៃឡង់ ប្រទេស វៀតណាម និងឡាវ) គឺម្នាក់ៗ បានទទួលនូវភាគថ្មីមួយ នៃ"នំ"ខ្មែរ ។

ជាឧទាហរណ៍ យើងបានឃើញភូមិករយ៉ាងច្រើនឥតគណនា របស់ប្រជាជាតិយើង ដែលពីដើម ក្នុងរជ្ជកាលសង្គមរាស្ត្រនិយម ថិតនៅក្នុងទឹកដីរបស់ប្រទេសកម្ពុជា អំណើះតទៅ គួរឱ្យស្តាយ! (៣ដង) វាត្រូវថិតនៅក្នុងសាធារណរដ្ឋសង្គមនិយមវៀតណាមវិញ (វៀតណាមខាងត្បូង) និងត្រូវបានការពារយ៉ាងមាំទាំ ដោយកងទ័ព (ដែលគេមិនអាចនរណាយកជ័យជំនះទៅលើបាន) នៃ "បងប្អូនវៀត"យើង ។

ក្នុងពេលថ្មីៗនេះ លោកមេធាវី **មីស្សែល ប៊ុស្សុង** និងមិត្តរបស់លោក បានឃើញដោយផ្ទាល់ ការដែល "បងប្អូនវៀត"នោះ បានក្លាយខ្លួនជាម្ចាស់ នៅលើភូមិកររបស់ខ្មែរ ដោយហេតុតែការក្រខ្សត់ជាទីបំផុតនោះ បងប្អូនរួមជាតិរបស់យើង ជាអ្នកតូចតាចទាំងនោះ បានសម្រេចចិត្តជួល ឬមួយអាក្រក់ជាងនេះទៅទៀត បានលក់ទៅឱ្យ"បងប្អូនវៀត" ។ តាមការដែលលោក មីស្សែល ប៊ុស្សុង បានឃើញដោយខ្លួនលោកផ្ទាល់ "បងប្អូនវៀត" ទាំងនោះបានបង្ខិត"ព្រំដែនថ្មី" នៃ"វៀតណាមខាងត្បូង"របស់គេនោះ ចូលមកយ៉ាងជ្រៅមកក្នុងប្រទេសកម្ពុជា "រាជាណាចក្រទី ២" ។

*

*        *

គឺជាការពិត នៅក្រោមរដ្ឋអំណាច លន់ នល់ (សាធារណរដ្ឋខ្មែរ) ជនជាតិវៀតណាម ដែលរស់នៅ។ "វៀតណាមខាងត្បូង" (កម្ពុជាក្រោម) ពួកគេតែងធ្វើរលិខិតមកពួក"វៀត" ដែលរស់នៅ នៅស្វាយរៀង ដោយបានការស្រោមសំបុត្ររបស់គេរៀង។ខ្លួន យ៉ាងច្បាស់ឥតសង្ស័យបានថា :"ស្វាយរៀង- វៀតណាម" sic ! ។

ជាការពិតដែរ កងទ័ពរបស់ ង្វៀង វ៉ាន់ ធីវ ដែលនៅពេលនោះ បានកាន់កាប់ ក្រុងនាក់លឿង យើងគេបាន ប្រសិទ្ធិនាមទីនោះយ៉ាងខ្លីថា : "សាយក្ងងម៉ីយ" គឺព្រៃនគរថ្មី (ជាអង់គ្លេស NEWSAIGON, ជាបារាំង NOUVEAU SAIGON) ។

*

*  *

វិលមករឿងរបស់លោក មីស្ហែល ប៊ុស្សុង វិញ លោកបានឃើញទាហានវៀតទាំងនោះ ប្រកាន់ឫកជាចៅហ្វាយទាំងស្រុង មកលើប្រជាជនខ្មែរ ដែលរស់នៅ នៅទីប្រជុំជនស្នួល របស់ខ្មែរ ។
សាធារណរដ្ឋសង្គមនិយមវៀតណាម បាន"បង្កើត"ព្រំដែនថ្មី។ជាច្រើន (ជាប្រយោជន៍ដល់គេ) ដោយបានសាងសង់ នៅក្នុងទសវត្សរ៍១៩៨០ និង១៩៩០-២០០០ នូវ" ខ្លោងទ្វា "ជាច្រើន និងបានជីកព្រែក ជាច្រើនទៀត ចូលយ៉ាងជ្រៅ មកក្នុងប្រទល់ដែនយើង ឆ្នាំ១៩៦៣-១៩៦៩ ។

ចំណែកប្រទេសថៃឡង់វិញ នៅក្នុងខេត្តខ្លះ។ នៃប្រទេសកម្ពុជា" រាជាណាចក្រទី២ " គេបាន"បង្កើត"ព្រំប្រទល់ដែនថ្មី។ (ជាប្រយោជន៍គេ) ដោយបានលើកផ្លូវយ៉ាងធំ។ ត្រង់ព្រិញ កាត់ក្នុងទឹកដីយ៉ាងធំ ដែលជារបស់យើង ដោយពេញច្បាប់ ។ ដីដែលនៅប៉ែកជិតទៅខាងប្រទេសថៃឡង់ ដែលចិតនៅតាមដងផ្លូវ ដែលមានថែងខាងនីនេះ អំណើះតទៅ "ជាកម្មសិទ្ធិ "របស់ព្រះរាជាណាចក្រថៃ ។

*

*  *

ក្នុងពេលបច្ចុប្បន្ននេះ ការដែលក្រុមលោក ឯ.ឧ. **វ៉ា គិម ហុង** "ធ្វើការ"ជាផ្លូវការជាមួយនឹង អ្នកជិតខាងរបស់យើងទាំង៣ ដើម្បីឱ្យបានដឹងថា តើព្រំប្រទល់របស់ខ្មែរយើង **<u>នៅត្រង់ណា</u>**នោះ នេះជាភស្តុតាងមួយយ៉ាងច្បាស់ ដែលបង្ហាញថា :

ទី១ : សាធារណរដ្ឋសង្គមនិយមវៀតណាម ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជា-មានិតឡាវ មិនទទួស្គាល់ឡើយ នូវភាពត្រឹមត្រូវនិងភាពស្របច្បាប់នៃព្រំប្រទល់ ដែនរបស់ប្រទេសកម្ពុជា ឆ្នាំ១៩៦៣ ដល់ ១៩៦៩ (សូម្បី ក្នុងសន្និសិទកំពូលនៃប្រជាជាតិឥណ្ឌូចិន ដែលបានធ្វើនៅកង់តុង គណៈ-ប្រតិភូរបស់រដ្ឋាភិបាលបណ្ដោះអាសន្នវៀតណាមខាងត្បូង (ប្រធានាធិបតី ង្វៀង ហ៊ឺ ថ) គណៈប្រតិភូ

សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (រដ្ឋមន្ត្រីទី១ ផាំ វ៉ាន់ ដុង) និងគណប្រតិភូណេអូឡាវហាក់សាត នៃប្រទេសឡាវ (ព្រះអង្គម្ចាស់  ស៊ូផានុវង់) បានទទួស្គាល់ដោយជាក់លាក់ និងជាឧឡារឹក នៅចំពោះមុខ លោករដ្ឋមន្ត្រីទី១ ជូ អេន ឡាយ (សាធារណរដ្ឋប្រជាមានិតចិន) និងចំពោះមុខខ្ញុំ (ប្រមុខរដ្ឋពេញច្បាប់ នៃប្រទេសកម្ពុជា) នូវគំនូសព្រំដែនប្រទេសកម្ពុជា ឆ្នាំ១៩៦៣-១៩៦៩ ហើយថែមទាំងបានសន្យា ជាឧឡារឹក ក្នុងនាមប្រទេសជាតិ និងប្រជារាស្ត្ររបស់ខ្លួនរៀង១ខ្លួន ថានឹងគោរពជានិច្ច ជានិរន្តតទៅ នូវគំនូសព្រំដែនរបស់យើងនោះ ក៏ដោយ) ។

ទី២ : ប្រទេសកម្ពុជាយើង “ រាជាណាចក្រទី២ ” ដោយខ្លួនឯង (ដែតំណាងដោយក្រុមឯឧ. វ៉ា គិមហុង) បានសុខចិត្តទទលួធ្វើ**អត្តឃាដ** ដោយហេតុបានទទួស្គាល់ ទាំងនៅចំពោះមុខច្បាប់អន្តរជាតិផង ថាប្រទេសកម្ពុជាពុំមានព្រំប្រទល់ដែនច្បាស់លាស់នោះឡើយ ។

ដោយសារការសុខចិត្តជាផ្លូវការ ទទួយល់ព្រមចរចាគ្មាសារជាថ្មី នៅលើបញ្ហាព្រំដែន ប្រទេសកម្ពុជានៃសម័យ“ក្រោយអង្គរ ”យើង  ទទួលស្គាល់ថា សូម្បីខ្លួនឯង ក៏មិនដឹងដែរថា តើព្រំប្រទល់ដែនរបស់ខ្លួន ទាំងខាងដែនដីគោក ទាំងខាងដែនសមុទ្រ នៅត្រង់ណា ។

នៅចំណុចនេះ ពាក្យថា“**អត្តឃាដ** ” មិនមានន័យហួសហេតុឡើយ អាស្រ័យហេតុថា ប្រទេសណាមួយ ដែលទទួស្គាល់ថា ខ្លួនពុំមានព្រំប្រទល់ដែនច្បាស់លាស់ ហើយត្រឹមត្រូវតាមច្បាប់នោះ ប្រទេសនោះជាប្រទេស **ស្លាប់** ៕